# កម្រងចម្លើយតបពាក់ព័ន្ធ
# ការអនុវត្តន៍លើសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស
## ស្តីពី "Le travail et l`emloi des personnes handicapée"

១. តើរដ្ឋធម្មនុញ្ញ ឬ នីតិបញ្ញត្តិថ្នាក់ជាតិ ឬថ្នាក់មូលដ្ឋាននៃប្រទេសរបស់លោកអ្នក បានលុបបំបាត់របាំងផ្សេងៗ ដែលរាំងស្ទះ ឬក៏រឹតបន្តឹងការបញ្ចូលសិស្សពិការ ក្នុងប្រព័ន្ធអប់រំធម្មតា គ្រប់កំរិតដែរឬទេ? (ឧទាហរណ៍ ដោយពឹងផ្អែកលើមូលដ្ឋាននៃការធ្វើរោគវិច្ឆ័យ ឬក៏ការវាយតម្លៃទៅលើសមត្ថភាពរបស់ពួកគេ)។

រដ្ឋាភិបាលកម្ពុជាបានផ្តល់ការគាំទ្រ ការអប់រំសមស្របសម្រាប់អប់រំកុមារពិការ ដោយបានដាក់ចេញនូវច្បាប់ គោលនយោបាយ និងកម្មវិធីជាច្រើនរួមមានៈ ច្បាប់ស្តីពីការអប់រំ([១])បានអនុម័តកាលពីថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ច្បាប់ ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ([២]) បានអនុម័តកាលពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ អនុសញ្ញាស្តីពីសិទ្ធិជនពិការ([៣]) ត្រូវបានផ្តល់សច្ចាប័នកាលពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ ២០១២ និងបានចូលជាធរមាន កាលពីថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៣ ផែនការ សកម្មភាពជាតិស្តីពីជនពិការ រួមបញ្ចូលជនរងគ្រោះដោយសារគ្រាប់មីន និងកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមឆ្នាំ២០០៨ ដល់២០១១ និងបានបន្តរហូតដល់២០១៣ គោលនយោបាយស្តីពីការអប់រំកុមារពិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានអនុម័តនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០០៨ ផែនការមេ ស្តីពីការអប់រំកុមារពិការ ឆ្នាំ២០០៩ ដល់២០១១ កម្មវិធីអប់រំបញ្ចូលគ្នាកុមារពិការរបស់ក្រសួងអប់រំ យុវជន និងកីឡា ២០០៩ និង កម្មវិធីអប់រំបញ្ចូលគ្នាឆ្នាំ២០១២ ។

២. តើការអប់រំកុមារ និងមនុស្សពេញវ័យដែលមានពិការភាព ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអប់រំដែរឬទេ? សូមបញ្ជាក់ ប្រសិនបើក្រសួងផ្សេងៗទៀត (ដូចជាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល) មានសមត្ថកិច្ចគ្រប់គ្រងស្ថាប័នអប់រំមួយចំនួន ហើយនឹងសូមលំអិតអំពីមុខងាររបស់ក្រសួង។

វិស័យអប់រំនៃព្រះរាជាណាចក្រកម្ពុជា ៨០% គ្រប់គ្រងដោយក្រសួងអប់រំ យុវជននិងកីឡា ចាប់ពីការអប់រំកុមារតូច បឋមសិក្សា មធ្យមសិក្សា ដល់ឧត្តមសិក្សា។

---

[១] ច្បាប់ស្តីពីការអប់រំឆ្នាំ២០០៧

[២] ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនបិការ www.dac.org.kh

[៣] អនុសញ្ញាស្តីពីសិទ្ធិជនពិការទាញយកបានពី www.dac.org.kh

ទោះបីយ៉ាងនេះក្តីក្រសួង ស្ថាប័នសាធារណៈនានាបានបង្កើតវិទ្យាស្ថាន ឬមហាវិទ្យាល័យតាមជំនាញដូចជា៖

- ✓ វិទ្យាស្ថានជាតិសង្គមកិច្ច និងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការ (ភ្នំពេញថ្មី និងបន្ទាយព្រាប) គ្រប់គ្រងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ✓ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈជនពិការទាំង២៤ ខេត្តក្រុង គ្រប់គ្រងដោយក្រសួង កិច្ចការនារីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ល។

៣. តើប្រទេសរបស់លោកអ្នកមានរៀបចំផែនការ ឬក៏កម្មវិធីណាមួយ ដែលជួយលើកកម្ពស់ការផ្លាស់ប្តូរប្រព័ន្ធអប់រំ ទៅជាប្រព័ន្ធអប់រំមួយដែលបានដាក់បញ្ចូលនូវវិធានការណ៍ខ្លះៗ ឬក៏រាល់វិធានការណ៍ទាំងអស់ ដែលមានរៀបរាប់ដូចខាងក្រោម? (សូមបង្ហាញតើមានវិធានការណ៍អ្វីខ្លះ?)៖

a) រួមបញ្ចូលថវិកា និងរដ្ឋបាលនៃការសិក្សាជំនាញនិងការសិក្សាធម្មតានៅក្នុងតំបន់ភូមិសាស្ត្រមួយដែលផ្តល់អោយ។

ក្រសួងអប់រំ យុវជន និងកីឡា បានយកចិត្តទុកដាក់អប់រំចំណេះដឹងទូទៅ ក្នុងគោលបំណងកាត់បន្ថយឧបសគ្គនៃការចូលរៀន ដើម្បីកែលម្អគុណភាពនិងប្រសិទ្ធភាពនៃការអប់រំ ធានាការចូលរៀនប្រកបដោយសមធម៌នៅមធ្យមសិក្សាទុតិយភូមិ ក្រោយពីប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ។ ដើម្បីសម្រេចគោលបំណងនេះបានក្រសួងបានរៀបចំថវិកាពីរផ្នែក គឺសម្រាប់កម្មវិធីចរន្ត និងកម្មវិធីមូលធន។

១- <u>កម្មវិធីចរន្ត</u> ផ្តោតលើដំណើរការសាលារៀននៅទូទាំងប្រទេស ការសម្របសម្រួលកញ្ចប់ថវិកាប្រចាំឆ្នាំ និង រូបមន្តបែងចែកថវិកា ការលើកទឹកចិត្តសិស្សពូកែប្រចាំឆ្នាំ ការតាមដាន វាយតម្លៃ ការរៀបចំផែនការប្រលង ការគ្រប់គ្រងបណ្ណាល័យ។ល។

២. <u>កម្មវិធីមូលធន</u> ដោយវិនិយោគលើការផ្តល់មធ្យោបាយទំនាក់ទំនងសម្រាប់ថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ផ្តល់ថវិកាដំណើរការវិទ្យាល័យធនធាន ក្នុងដំណាក់កាលពីរឆ្នាំដំបូង និងផ្ទេរការទទួលខុសត្រូវ ដល់ក្រសួងនៅឆ្នាំបន្តបន្ទាប់ ផ្តល់ថវិកាប្រតិបត្តិសម្រាប់សាលាកុមារមេត្រី និងកិច្ចសហប្រតិបត្តិការ([៤])។

កន្លងមកក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលនយោបាយ និងផែនការមេឯកសារបណ្តុះបណ្តាលស្តីពីការអប់រំសម្រាប់កុមារពិការ ដោយប្រើប្រាស់ថវិកាចរន្ត។

[៤] <u>ការអប់រំចំណេះទូទៅ</u>

ក្រុមប្រឹក្សាសកម្មភាពជនពិការបាននឹងកំពង់រៀបចំផែនការយុទ្ធសាស្ត្រជាតិ ស្តីពីពិការភាពឆ្នាំ២០១៤ ដល់ ២០១៨ សម្រាប់អនុវត្តក្នុងការលើកវិស័យពិការភាពទូទាំងប្រទេសកម្ពុជា។ ផែនការនេះនឹងដាក់បញ្ចូលការការទទួលខុសត្រូវរបស់រដ្ឋក្នុងការបណ្តុះបណ្តាលជំនាញប្រកបដោយគុណភាព ជូនដល់ជនពិការនៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវរបស់រដ្ឋ។

b) ប្រើប្រាស់ធនធានដែលមាន ពាក់ព័ន្ធនឹងការសិក្សាអប់រំជំនាញ នៅក្នុងសាលារៀន ឬនៅក្នុងថ្នាក់ជំនាញ ដោយផ្អែកលើប្រព័ន្ធអប់រំទូទៅ ដើម្បីបញ្ចូលសិស្សពិការ។

ក្រសួងអប់រំ យុវជន និងកីឡា (អ.យ.ក.) បានរៀបចំ និងដាក់ឲ្យប្រើប្រាស់សេចក្តីណែនាំស្តីពីការអនុវត្តមុខវិជ្ជាជីវៈបន្ថែម នៅសាលាចំណេះទូទៅ ឆ្នាំ២០១១ ផែនការអប់រំបច្ចេកទេសវិជ្ជាជីវៈឆ្នាំ២០១១ លិខិតបទដ្ឋានសម្រាប់ពង្រីកវិទ្យាល័យឲ្យទៅជាវិទ្យាល័យវិជ្ជាជីវៈឆ្នាំ២០១២ សេចក្តីណែនាំស្តីពីការតម្រង់ទិសវិជ្ជាជីវៈឆ្នាំ២០១៣ សេចក្តីណែនាំស្តីពីការអនុវត្តមុខវិជ្ជាជំនាញ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ (ICT) នៅតាមបណ្តាវិទ្យាល័យនានា និងគោលនយោបាយបំណិនជីវិត ២០១២([៥])។ មានថវិកាគម្រោង [Program Budgetting (PB)] សម្រាប់ការងារអប់រំផ្តល់ទៅសាលាបឋម និងមធ្យមសិក្សា ដោយផ្តោតលើការងាររដ្ឋបាល និងការងារបច្ចេកទេស ដោយរួមទាំងការសិក្សារបស់កុមារពិការផងដែរ។ សាលានីមួយៗមានសិទ្ធិចាត់ចែងថវិកា (PB) នេះសម្រាប់ការអប់រំពិសេស ឬអប់រំបញ្ចូលគ្នារបស់សិស្សពិការតាមទំហំតម្រូវការរបស់គេ។

អង្គការដែលធ្វើការលើការអប់រំសិស្សពិការ បានផ្តល់ការអប់រំពិសេសនៅតាមតំបន់គោលដៅរបស់ខ្លួន ដោយមានការសហការយ៉ាងស្និតជិតជាមួយក្រសួងអប់រំ យុវជន និងកីឡា។

c) បណ្តុះបណ្តាលគ្រូអប់រំជំនាញ ដើម្បីអោយគ្រូទាំងនេះជួយបង្ហាត់បង្រៀនបន្ថែមដល់គ្រូបង្រៀនធម្មតា។

ក្រសួងអប់រំ យុវជន និងកីឡា បានសម្របសម្រួល និងធ្វើការគាំទ្រការបណ្តុះបណ្តាលជំនាញ ក្នុងគោលបំណងបង្កើនសមត្ថភាពដល់លោកគ្រូអ្នកគ្រូពាក់ព័ន្ធនានា ដើម្បី ឲ្យពួកគេបន្តផ្តល់ការអប់រំពិសេស ដល់កុមារពិការតួយ៉ាងដូចជាអង្គការគ្រួសារថ្មី អង្គការឌីឌីភី ដែលជាសមាជិករបស់ក្រុមប្រឹក្សាសកម្មភាពជនពិការបានរៀបចំសាលារៀនពិសេស សម្រាប់កុមារពិការភ្នែក កុមារ គ-ថ្លង់។ កុមារទាំងនោះបាន

[៥] យុទ្ធសាស្ត្រជាតិស្តីពីការអប់រំ ១.៧ កម្មវិធីតម្រង់ទិសវិជ្ជាជីវៈ

សិក្សាអក្សរស្ទាប និងភាសាសញ្ញា(6) ត្រឹមកម្រិតថ្នាក់ទី៣ លុះពួកគេបន្តដល់ថ្នាក់ទី៤ ពួកគេត្រូវបានដាក់បញ្ចូលក្នុងថ្នាក់ធម្មតា។ នៅថ្នាក់ណាដែលមានកុមារពិការ (គ-ថ្លង់) ត្រូវមានគ្រូពីរគឺគ្រូបន្ទុកថ្នាក់ និងគ្រូជំនួយក្នុងការបកប្រែភាសាសញ្ញា។

ដើម្បីបង្កើនប្រសិទ្ធភាពនៃការអប់រំសម្រាប់កុមារ វគ្គបណ្តុះបណ្តាលអំពីការអប់រំបញ្ចូលគ្នា និងអប់រំពិសេស ត្រូវបានផ្តល់ជូនដល់គរុនិស្សិត និងគរុសិស្ស ចំនួន ១៥ ០០០នាក់ នៅសាលាគរុកោសល្យរាជធានី ខេត្ត និងមណ្ឌលគរុកោសល្យភូមិភាគ គ្រូបង្រៀនសរុបចំនួន ៧០ ០០០នាក់ ក្នុងនោះមាន ៤០% បានទទួលការបណ្តុះបណ្តាលអំពីការអប់រំពិសេស និងអប់រំបញ្ចូលគ្នា(៧)។

d) ផ្លាស់ប្តូរជាបន្តបន្ទាប់ នូវសិស្សដែលរៀននៅក្នុងកម្មវិធីជំនាញ ទៅជាថ្នាក់រៀនធម្មតា ដោយអាស្រ័យលើបុគ្គលិកគរុកោសល្យ។

បច្ចុប្បន្នមានកម្មវិធីអប់រំពិសេសដែលដំណើការដោយអង្គការមិនមែនរដ្ឋាភិបាល នៅតាមបណ្តារាជធានី/ខេត្តមួយចំនួន។ កម្មវិធីអប់រំពិសេសទាំងនេះ មានពីរកម្រិតមត្តេយ្យដល់បឋមសិក្សា។ ក្រោយពីការបញ្ចប់បឋមសិក្សា ពួកគេត្រូវបានសមាហរណកម្មចូលក្នុងសាលារដ្ឋ។ គ្រូនៅសាលាអប់រំពិសេសជាអតីតគរុនិស្សិតដែលបានបណ្តុះបណ្តាលគរុកោសល្យ និងការអប់រំពិសេសសម្រាប់សិស្សពិការ(៨)។

e) ប្រើប្រាស់ធនធានហិរញ្ញវត្ថុទៅលើការទទួលបន្ទុកដ៏ត្រឹមត្រូវមួយ សម្រាប់សិស្សទាំងអស់ ដោយរាប់បញ្ចូលទាំងការរៀបចំដ៏សមស្របផងដែរ ហើយនឹងទៅលើជំនួយបច្ចេកទេស ដើម្បីគាំទ្រមន្ត្រីក្រសួងអប់រំកម្រិតមូលដ្ឋាន នៅសាលារៀន និងនៅក្នុងថ្នាក់រៀន។

រាជរដ្ឋាភិបាលបានរៀបចំកញ្ចប់ថវិកា ដើម្បីឲ្យក្រសួងអប់រំ យុវជន និងកីឡា ប្រើប្រាស់ជាគម្រោង គាំទ្រអនុវត្តគោលនយោបាយលើកកម្ពស់ធនធានមនុស្សលើវិស័យអប់រំចាប់តាំងពីថ្នាក់ជាតិ ដល់ថ្នាក់ក្រោមជាតិ(៩)។ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការហិរញ្ញវត្ថុក្នុងការលើកកម្ពស់សមត្ថភាពបុគ្គលិក សិក្សារួមមាន៖

---

[៦] គោលនយោបាយស្តីពីការអប់រំកុមារពិការ(back ground)

[៧] របាយការណ៍ផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ២០០៩ ដល់២០១៣ ផ្ទៀងផ្ទាត់ដោយក្រសួងអប់រំ

[៨] របាយការណ៍ គ្រូសារថ្មី ឡាវាឡា ២០១៣

[៩] Policy on Human Resource in Education Sector (Ministry of Education, youth and sport)

កម្មវិធីចរន្ត៖ កម្មវិធីនេះរួមមាន ថវិកាសម្រាប់គរុកោសល្យ កម្មវិធីអភិវឌ្ឍន៍សមត្ថភាពគ្រប់គ្រងអប់រំ កម្មវិធីអភិវឌ្ឍ/វិក្រឹតការគ្រូបង្រៀន និងកម្មវិធីតាមដាន និងវាយតម្លៃ។

កម្មវិធីមូលធន៖ កម្មវិធីនេះផ្តោតជាពិសេសលើកិច្ចសហប្រតិបត្តិការបច្ចេកទេស។ កម្មវិធីមូលធនចែកចេញជាវិនិយោគ ដែលសំដៅលើការបំពាក់ឧបករណ៍ បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍(ICT) នៅតាមសាលាគរុកោសល្យ ខណៈដែលកម្មវិធីកិច្ចសហប្រតិបត្តិការបច្ចេកទេសដែលផ្តោតជាសំខាន់លើការងារគ្រប់គ្រង ការបង្កើនសមត្ថភាពគរុកោសល្យ/វិក្រិតការ និងការប្រើប្រាស់ឧបករណ៍([១០])។

f) ពិនិត្យឡើងវិញនូវវិធីសាស្ត្រវាយតម្លៃ៖ (១) ដើម្បីធានាការដាក់បញ្ចូលសិស្សពិការ។ (២) ដើម្បីអោយនិស្សិតទាំងនោះទទួលបានវិញ្ញាបនបត្រសមស្រប ហើយនិងដើម្បីឈានអោយបានដល់កម្រិតឧត្តមសិក្សា ឬទទួលបានសញ្ញាបត្រក្រោយបញ្ចប់ការសិក្សារបស់ពួកគេ។

(១)ដើម្បីពង្រឹងប្រសិទ្ធភាពនៃការអប់រំបញ្ចូលគ្នា ក្រសួងអប់រំយុវជន និងកីឡា បានរៀបចំក្រុមការងារអនុវត្តថ្នាក់ជាតិ និងថ្នាក់រាជធានី ខេត្ត [Provincial Implement Teams (PITs)]។ ក្រុមការងារនេះមានតួនាទី និងភារកិច្ចចាត់ចែង សម្របសម្រួល និងត្រួតពិនិត្យការអនុវត្តអប់រំបញ្ចូលគ្នា [Inclusive Education (IE)] របស់កុមារពិការគ្រប់រាជធានី ខេត្ត។

(២) ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំគោលការណែនាំ ដើម្បីគាំទ្រការអប់រំបញ្ចូលគ្នារបស់ជនពិការ ដោយដាក់ឲ្យអនុវត្តវិធីសាស្ត្រមិត្តជួយមិត្តក្នុងសាលា ប្រើប្រាស់មូឌុលជំនួយក្នុងការបង្រៀន ដើម្បីលើកកម្ពស់សមត្ថភាពគ្រូក្នុងការបង្រៀន និងប្រើប្រាស់គ្រឿងជំនួយសម្រាប់ការសិក្សានានា ដែលកម្មវិធីទាំងនេះ ស្ថិតក្នុងគោលនយោបាយស្តីពីសាលាកុមារមេត្រី([១១])។

ចំពោះការទទួលសញ្ញាបត្រស្តីពីការ អប់រំចំណេះដឹងទូទៅ កុមារ និងយុវជន ត្រូវឆ្លងកាត់ការប្រឡងដូចកុមារដទៃទៀតដែរ ទៅតាមប្រភេទពិការនិងដោយប្រើប្រាស់ភាសាសញ្ញា អក្សរស្ទាប និងមធ្យោបាយជំនួយផ្សេងៗ។

[១០] ក្រសួងអប់រំ (បណ្តុះបណ្តាលគ្រូបង្រៀន )

[១១] គោលនយោបាយស្តីពីការអប់រំកុមារពិការ របស់ក្រសួងអប់រំ យុវជន និងកីឡា

g) ធ្វើការបណ្តុះបណ្តាលបឋម និងវគ្គសិក្សាស្តីពីការងារ ដល់គ្រូបង្រៀន ដើម្បីអោយពួកគេអាចមានសកម្មភាពប្លែកៗ នៅក្នុងថ្នាក់រៀន (ឧទាហរណ៍ បណ្តុះបណ្តាលគ្រូអំពីបច្ចេកទេសនៃការទទួលបន្ទុកក្នុងថ្នាក់រៀន ដូចជាការបង្រៀនប្លែកៗ និងការរៀនបែបសហការគ្នា)។

រៀងរាល់ឆ្នាំក្រសួងអប់រំ យុវជននិងកីឡា បានសហការជាមួយនិងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការអប់រំលើវិស័យពិការភាព រៀបចំវគ្គបណ្តុះបណ្តាលស្តីពីល្បែងសិក្សា ដល់គ្រូថ្នាក់បឋមសិក្សាដើម្បីឲ្យពួកគេបន្តបង្រៀនល្បែងទាំងនេះបញ្ចូលក្នុងសកម្មភាពបង្រៀនសម្រាប់ថ្នាក់របស់រៀងៗខ្លួន។

រដ្ឋាភិបាលមានថវិកាដំណើរការប្រចាំឆ្នាំ ដល់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមសាលាគរុកោសល្យ និងវិក្រឹតការរាជធានី-ខេត្តទាំង១៨មជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគទាំង៦ និងមជ្ឈមណ្ឌលធនធានចំនួន៦ សំដៅកែលម្អគុណភាព និងប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការគ្រូបង្រៀន។ អាទិភាពមួយសម្រាប់សាលាគរុកោសល្យ គឺការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតមូលដ្ឋានដើម្បីឆ្លើយតបប្រកបដោយភាពទន់ភ្លន់ ទៅនឹងការប្រែប្រួលការចូលរៀននៅបណ្តាឆ្នាំខាងមុខនេះ។

ផ្តល់ឱ្យនាយកសាលាបឋមសិក្សា និងមធ្យមសិក្សានូវជំនាញនានា ដើម្បីការអនុវត្ត ការដឹកនាំសកម្មនិងទទួលខុសត្រូវក្នុងការអនុវត្តវិធានការនានា និងគ្រប់គ្រងធនធានប្រកបដោយប្រសិទ្ធភាព និងគុណភាពតាមរយៈកម្មវិធីបំប៉នសមត្ថភាពគ្រប់គ្រងអប់រំគ្រប់កម្រិត។

h) តាមដានយ៉ាងយកចិត្តទុកដាក់រាល់ឧបសគ្គ ដែលរាំងស្ទះដល់ការបង្រៀនរបស់គ្រូ (ឧទាហរណ៍ កាត់បន្ថយចំនួនសិស្ស ពិនិត្យឡើងវិញនូវខ្លឹមសារមេរៀនតាមរយៈការអនុវត្តដ៏ល្អប្រសើរ ត្រួតពិនិត្យមើលថាតើកុមារពិការបានទទួលនូវអគារ និងសម្ភារៈសិក្សាដែរឬទេ)។

ដើម្បីដោះស្រាយបញ្ហាប្រឈម ក្រសួងអប់រំបានប្រគល់តួនាទីរបស់នាយកដ្ឋានជំនាញនិងមន្ទីរតាមរាជធានីខេត្តរួមមាន៖

គ្រប់នាយកដ្ឋានចំណោះទូទៅ មានតួនាទីគ្រប់គ្រងការអភិវឌ្ឍអនុត្តន៍ វិស័យអប់រំតាមកម្រិតរបស់ខ្លួន ដោយផ្តោតលើ ការធ្វើផែនការ ការពង្រឹងប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃ ការប្រើប្រាស់ធនធាន និងការកសាងសមត្ថភាព។ នាយកដ្ឋាន

មធ្យមសិក្សាចំណោះទូទៅផ្តល់ជំនួយទាំងបច្ចេកទេស និងការគ្រប់គ្រងដល់ថ្នាក់ក្រោមជាតិដើម្បីអនុវត្តនូវតួនាទី និងភារកិច្ចរបស់គេ។

មន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្តទទួលខុសត្រូវរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំសម្រាប់អនុវិស័យ អនុវត្តគ្រប់សេចក្តីណែនាំរបស់ថ្នាក់ជាតិ និងជួយដល់សាលារៀនទាំងផ្នែកបច្ចេកទេស រដ្ឋបាល និងគ្រប់គ្រង រួមទាំងកិច្ចការហិរញ្ញវត្ថុ។

ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌទាំង ១៩៣ ជួយសម្របសម្រួលផ្នែករដ្ឋបាល។ សាលាមធ្យមសិក្សានីមួយៗទទួលខុសត្រូវរៀបចំកសាងនិងអនុវត្តផែនការអភិវឌ្ឍសាលារៀន ដោយមានការចូលរួមពេញលេញពីសហគមន៍ និងស្របតាមគ្រប់ការណែនាំពីថ្នាក់ជាតិ។ គ្រប់គ្រង និងអនុវត្តរាល់កម្មវិធីជាតិដែលថ្នាក់ជាតិបានកំណត់ឲ្យសាលារៀន។ ពង្រឹងអភិបាលកិច្ចល្អ និងការគ្រប់គ្រងសាលារៀន។

សុំការអនុញ្ញាត្តិពីថ្នាក់ជាតិរាល់ការអនុវត្តសកម្មភាពផ្សេងៗ ដែលអាចមានការប៉ះពាល់ដល់ការសិក្សារបស់សិស្សពីសំណាក់អង្គការមហាជននានា។ អនុវត្តចំនួនសិស្សតាមនិយាម ដែលបានដាក់ចេញដោយក្រសួងអប់រំ យុវជន និងកីឡា។

i) ទទួលស្គាល់ភាសាសញ្ញាជាភាសាផ្លូវការ ព្រមទាំងអប់រំអ្នកប្រើប្រាស់ភាសាសញ្ញាជាភាសាផ្ទាល់ខ្លួនរបស់ពួកគេ នៅក្នុងសាលារៀនធម្មតា។

ក្រសួងអប់រំបានចេញប្រកាសក្នុងការអនុញ្ញាតប្រើប្រាស់ និងបោះពុម្ពជាផ្លូវការភាសាសញ្ញានេះ អក្សរស្ទាប អាចប្រើប្រាស់គ្រប់កម្រិត និងគ្រប់មុខវិជ្ជា ស្របតាមកម្មវិធីអប់រំបញ្ចូលគ្នា ក្រោយពីក្រសួងបានត្រួតពិនិត្យ កែលម្អឲ្យមានលក្ខណៈសុក្រឹត្យរួច។ អក្សរស្ទាប និងភាសាសញ្ញា ត្រូវបានផ្តល់ដល់គរុនិស្សិត គរុសិស្ស និងគ្រូកំពុងបម្រើការងារដើម្បីកែលម្អសេវាអប់រំសម្រាប់កុមារពិការភ្នែក និងគ-ថ្លង់។

ដោយមានការសហការល្អរវាងអង្គការមិនមែនរដ្ឋាភិបាល ក្រសួងអប់រំបានរៀបចំវគ្គបណ្តុះបណ្តាលដល់សាលាសាធារណៈចំណោះទូទៅរួមមាន៖

- សហការជាមួយអង្គការគ្រួសារថ្មី បានផ្តល់ការអប់រំអក្សរស្ទាប និងភាសាសញ្ញា ជូនដល់ សាលារដ្ឋចំនួន ១៥០ និងគ្រូបង្រៀននៃអង្គការគ្រួសារថ្មី
- សហការជាមួយអង្គការគ្រួសារថ្មី បានបកប្រែកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ ទៅជាអក្សរស្ទាប និងភាសាសញ្ញា

- សហការជាមួយអង្គការគ្រួសារថ្មី បានបណ្តុះបណ្តាលគ្រូឧទ្ទេស ២២នាក់ អំពីអក្សរស្ទាប និងភាសាសញ្ញា
- សហការជាមួយអង្គការគ្រួសារថ្មី បានឧបត្ថម្ភថវិកាលើកទឹកចិត្តបន្ថែមជារៀងរាល់ខែដល់ គ្រូបង្រៀនអក្សរស្ទាប និងភាសាសញ្ញានៅសាលារដ្ឋចំនួន ១៣៨ សម្រាប់ ជួយដល់សិស្សពិបាកក្នុងការស្តាប់ និងមើល នៅតាមសាលារដ្ឋ និងសាលាគ្រួសារថ្មី
- កម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់ បានបង្កើតសៀវភៅភាសាសញ្ញាកម្ពុជាចំនួន ៥កម្រិត សម្រាប់ចែកចាយដល់ឪពុកម្តាយកុមារខ្សោយការស្តាប់ និងតាមសហគមន៍
- វចនានុក្រមភាសាសញ្ញាកម្ពុជាចំនួន ៥០០ច្បាប់ បាននិងកំពុងបោះពុម្ពផ្សាយ
- សម្ភារៈបង្រៀនអក្សរស្ទាបចំនួន ២១៨៨ច្បាប់ បានផ្សព្វផ្សាយតាមក្រុមគោលដៅក្នុងសាលារដ្ឋ សិស្សខ្សោយគំហើញ ៣០០នាក់ និងគ្រូបង្រៀន([១២])។

j) ធានាការឧបត្ថម្ភគាំទ្រដល់ការចូលរៀននៅក្នុងសាលារៀនធម្មតាមួយ ក៏ដូចជាវិធានការណ៍រៀបចំដ៏សមស្របមួយតាមរយៈសំណើររបស់បុគ្គលដែលពាក់ព័ន្ធ

ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ឱកាសដល់កុមារពិការ និងយុវជនពិការ ក៏ដូចជាការផ្សព្វផ្សាយ និងជំរុញឲ្យជនពិការគ្រប់ប្រភេទ បានចូលរៀននៅគ្រប់ភូមិសិក្សាដោយឥតបង់ថ្លៃចំពោះសាលាសាធារណៈ ដោយប្រើប្រាស់ថវិកាគម្រោង(PB)។

អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនដែលធ្វើការលើវិស័យពិការភាព ក៏បានរួមចំណែកយ៉ាងសកម្មក្នុងការជំរុញការយល់ដឹងអំពីការសិក្សារបស់កុមារ និងយុវជនពិការដល់ក្រុមគ្រួសារ និងសហគមន៍ តាមរយៈផ្តល់ការប្រឹក្សាយោបល់ដោយផ្ទាល់ ប្រើប្រាស់ឧបករណ៍ផ្សព្វផ្សាយនៅតាមសហគមន៍ និងប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ។

k) ជួយអង្គការរបស់ជនពិការ អង្គការសង្គមស៊ីវិល ជាពិសេសអង្គការរបស់ឪពុកម្តាយជនពិការ ក្នុងការពង្រឹងសមត្ថភាពរបស់ពួកគេ ទាក់ទងនឹងសិទ្ធិទទួលបានការអប់រំ និងវិធីសាស្រ្តគ្រប់គ្រងគោលនយោបាយនិងការអនុវត្ត។

សហការជាមួយដៃគូពាក់ព័ន្ធក្នុងការរៀបចំវគ្គបណ្តុះបណ្តាល និងរៀបចំសិក្ខាសាលាស្តីពីការងាររដ្ឋបាល ជំនាញក្នុងការសម្របសម្រួល សមត្ថភាពក្នុងការគ្រប់គ្រង

---

[១២] ប្រភពពីNPA report ផ្ទៀងផ្ទាត់ដោក្រសួងអប់រំ

ចាត់ចែង ត្រួតពិនិត្យ និងវាយតម្លៃដល់អង្គការមិនមែនរដ្ឋាភិបាល និងសមាគមរបស់ឪពុកម្តាយជនពិការ។

ក្រសួងអប់រំ យុវជន និងកីឡាបានចេញសេចក្តីណែនាំ ស្តីពីការបង្កើត និងដំណើរការរបស់គណៈកម្មការទ្រទ្រង់សាលាបឋមសិក្សា ដែលមានសមាសភាពចូលរួមពីតំណាងអាជ្ញាធរដែនដី អ្នកដឹកនាំសាសនា សប្បុរសជន នាយកសាលាបុគ្គលិកអប់រំចូលនិវត្តន៍ តំណាងសហគមន៍ អាជ្ញាធរមូលដ្ឋាន (១៣រូប)។ តួនាទីនិងភារកិច្ចរបស់គណៈកម្មការទ្រទ្រង់សាលារៀននេះ បានកំណត់ដោយប្រកាសរបស់ក្រសួងអប់រំ យុវជននិងកីឡាលេខ៣៤ អ.យ.ក/ស.ណ.ន ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១២។

៤. តើប្រទេសរបស់លោកអ្នកបានរៀបចំយន្តការទទួលខុសត្រូវ ដើម្បីត្រួតពិនិត្យលើការលុបឈ្មោះ ចុះឈ្មោះចូលរៀន និងការបញ្ចប់ការសិក្សារបស់ជនពិការ ដែរឬទេ? តើជនពិការ និងគ្រួសាររបស់ពួកគេត្រូវបានដាក់បញ្ចូលដោយផ្ទាល់ទៅក្នុងដំណើរការនេះ ដែរឬទេ?

រដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការអប់រំ ធានាកុមារទាំងឡាយ ដែលគ្រប់អាយុគឺត្រូវតែបានចូលរៀន ចាប់ពីអាយុ៦ឆ្នាំ វាមានទំនាក់ទំនងជាមួយការអប់រំពិសេស ក្រសួងអប់រំ យុវជន និងកីឡា កំពុងរៀបចំសេចក្តីព្រាងប្រកាសស្តីពីការអប់រំពិសេស ដើម្បីឲ្យកុមារពិការទាំងអស់ចូលរៀន ដោយស្មើភាព និងគ្មានការរើសអើង។ តាមរយៈ សេចក្តីព្រាងប្រកាសខាងលើ ឪពុកម្តាយ និងអ្នកអាណាព្យាបាលត្រូវបានលើកទឹកចិត្ត និងជំរុញដើម្បីបញ្ចូលកុមារពិការទាំងអស់ចូលរៀនដូចកុមារមិនជនពិការ។

ទាក់ទងនឹងការត្រួតពិនិត្យការចុះឈ្មោះ ការលប់ឈ្មោះ និងការបញ្ឈប់ការសិក្សារបស់សិស្សពិការ ក្រសួងបានប្រើប្រាស់យន្តការដែលមានស្រាប់ក្នុងការត្រួតពិនិត្យ រាល់សកម្មភាពសិក្សារបស់កុមារ និងយុវជនពិការ (សូមអានចណុច ៦)

៥. តើប្រទេសរបស់លោកអ្នកបានអនុម័តយន្តការ ដើម្បីវាយតម្លៃទិន្នន័យស្តីពីកុមារ និងមនុស្សពេញវ័យពិការ នៅក្នុងប្រព័ន្ធអប់រំ សម្រាប់គ្រឹះស្ថាននីមួយៗ (សាលារៀនធម្មតា សាលារៀនជំនាញ គ្រឹះស្ថានឬ ស្ថាប័នសង្គម ស្ថាប័នសុខភាពផ្លូវចិត្ត និងផ្សេងៗ) សម្រាប់ធ្វើជារបាំងជួយទប់ស្កាត់ ឬរឹតបន្តឹងមិនអោយបានចូលសាលារៀន (ការធ្វើដំណើរ ការចូលមកដល់ តម្លៃសេវាផ្សេងៗ)? សូមផ្តល់ទិន្នន័យដែលប្រើប្រាស់បាន។

ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំយន្តការមួយក្នុងការគ្រប់គ្រងប្រព័ន្ធប្រព័ន្ធព័ត៌មានទាក់ទងនឹងការអប់រំដែលមានឈ្មោះថា "ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ស្តី

ពីការអប់រំ (Education Management Information System (EMIS))។ យន្តការនេះមានតួនាទីគ្រប់គ្រងរាល់ព័ត៌មានអប់រំគ្រប់កម្រិត ជាពិសេសគ្រប់គ្រងលើទិន្នន័យសិស្សសិក្សាគ្រប់កម្រិត([១៣])ស្ថិតិកុមារពិការចូលរៀនថ្នាក់បឋមសិក្សាឆ្នាំសិក្សា ២០១១-២០១២ មានចំនួនសរុប៧០៦៤៨នាក់ ក្នុងនោះកុមារីពិការមានចំនួន ២៩២៩០នាក់([១៤])។

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ([១៥]) ស្តីពីការរៀបចំនិងប្រព្រឹត្តទៅរបស់ប្រឹក្សាសកម្មភាពជនពិការ(ក.ស.ជ) ដែលជាយន្តការសម្របសម្រួល និងពិគ្រោះយោបល់ថ្នាក់ជាតិលើវិស័យពិការភាព របស់រាជរដ្ឋាភិបាល។ ក.ស.ជ.មានអគ្គលេខាធិការដ្ឋានជាអ្នកអនុវត្តសកម្មភាពរបស់ខ្លួន។ ផ្នែកសិទ្ធិជនពិការ របស់អគ្គលេខាធិការដ្ឋាន ក.ស.ជ. មានតួនាទីនិងភារកិច្ចតាមដានអនុវត្តសិទ្ធិជនពិការ អនុសញ្ញាស្តីពីសិទ្ធិជនពិការនិងច្បាប់ជាធរមាននានា។

[១៣]មានតារាងទិន្នន័យជូនភ្ជាប់មកជាមួយ

[១៤]ស្ថិតិកុមារពិការកុមារពិការបានចូលរៀនដំណាច់ឆ្នាំ២០១១-២០១២

[១៥]អនុក្រឹត្យលេខ ២១៦អនក្រ.បក ចុះថ្ងៃទី២ខែឧសភាឆ្នាំ២០១៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅរបស់ប្រឹក្សាសកម្មភាពជនពិការ(ក.ស.ជ) www.dac.org.kh